## ឯកសារពិភាក្សា

# ផែនការពិការភាពនៃរដ្ឋវិចតូរីយ៉ា ឆ្នាំ២០១៧-២០២០

ដើម្បីទទួលបានឯកសារបោះពុម្ពផ្សាយនេះ សូមទូរស័ព្ទលេខ 1300 880 043 ដោយប្រើសេវា National Relay Service 13 36 77 ក្នុងករណីចាំបាច់ ofd@dhhs.vic.gov.au

អនុញ្ញាត និងបោះពុម្ពដោយរដ្ឋាភិបាលវិចតូរីយ៉ា 1 Treasury Place, Melbourne។

© រដ្ឋវិចតូរីយ៉ា ក្រសួងសុខាភិបាល និងសេវាមនុស្សសាស្ត្រ ខែឧសភា ឆ្នាំ២០១៦។

ពាក្យថា ‘ជនជាតិដើម “ ដែលបានប្រើក្នុងឯកសារនេះ គឺសំដៅទៅជនជាតិដើម និងប្រជាជនរស់នៅលើកោះ Torres Strait។ ពាក្យអន្តោគ្រាម ត្រូវបានរក្សាទុកពេលណាវាជាផ្នែកនៃចំណងជើងនៃរបាយការណ៍ កម្មវិធី ឬសម្រង់សម្តី។

ISBN/ISSN 978-0-7311-6910-8 (បោះពុម្ព)

Web only ISBN/ISSN 978-0-7311-6919-1 (pdf/អនឡាន)

មានផ្តល់ជូននៅតាមវ៉ិបសាយ www.statedisabilityplan.vic.gov.au

បោះពុម្ពដោយ Finsbury Green, Melbourne (1512022)

# អារម្ភកថារបស់រដ្ឋមន្ត្រី

ពលរដ្ឋអូស្ត្រាលីគ្រប់រូបមានសិទ្ធិទទួលបានសមភាព ក៏ប៉ុន្តែគួរឲ្យសោកស្តាយណាស់ដោយហេតុថាការនេះមិនមែនជាករណីជានិច្ចជាកាលឡើយ សម្រាប់ប្រជាពលរដ្ឋវិចតូរីយ៉ាជាង១.១លាននាក់ ដែលជាជនពិការ។ រដ្ឋាភិបាលគណៈបក្សការងាររបស់លោក Andrews បានប្តេជ្ញាចិត្តកែប្រែស្ថានភាពនេះ។

យើងប្តេជ្ញាចិត្តផ្តល់សិទ្ធិជូនពលរដ្ឋវិចតូរីយ៉ាជាជនពិការដើម្បីរស់នៅ ហើយចូលរួមក្នុងសង្គមរដ្ឋវិចតូរីយ៉ា ដូចគ្នានឹងមនុស្សគ្រប់រូបផ្សេងទៀតដែរ - ដែលទទួលបានការគាំទ្រចំពោះសេចក្តីប្រាថ្នារបស់ខ្លួន ចង់បានជីវភាពរស់នៅប្រចាំថ្ងៃដែលគេត្រូវបានវិនិច្ឆ័យតាមរយៈ កិច្ចខិតខំប្រឹងប្រែង និងសមិទ្ធិផលរបស់ខ្លួន។

រយៈពេលបួនឆ្នាំខាងមុខនេះគឺជាពេលវេលា និងឱកាសនៃការផ្លាស់ប្តូរយ៉ាងខ្លាំងអស្ចារ្យ ខណៈយើងផ្លាស់ប្តូរទៅ NDIS - គឺមិនត្រឹមតែសម្រាប់ជនពិការទេ គឺសម្រាប់សហគមន៍រដ្ឋវិចតូរីយ៉ាទាំងមូល។

ដើម្បីបង្កើនជាអតិបរមានូវអត្ថប្រយោជន៍ផ្នែកសង្គម និងសេដ្ឋកិច្ចរបស់ NDIS យើងត្រូវធ្វើកិច្ចការបន្ថែមទៀតក្នុងនាមជារដ្ឋមួយ - ក្នុងវិស័យសាធារណៈ និងឯកជននៅទីកន្លែងធ្វើការរបស់យើង សាលារៀន និងសហគមន៍របស់យើង - ដើម្បីធានាថា ជនពិការអាចចូលរួមយ៉ាងពេញលេញនៅក្នុងជីវិតប្រចាំថ្ងៃ។

នេះហើយគឺជាផែនការពិការភាពរបស់រដ្ឋ។

ចក្ខុវិស័យរបស់យើងគឺសម្រាប់រដ្ឋវិចតូរីយ៉ាដែលមានការផ្តត់ផ្តង់ជនពិការ ដើម្បីរស់នៅក្នុងជីវភាពប្រចាំថ្ងៃតាមបំណង។ ដោយមានការនេះនៅក្នុងគំនិត ឯកសារពិភាក្សានេះគូសបញ្ជាក់ពីចំណុចធំចំនួនបួន ដែលយើងត្រូវចាត់វិធានការដើម្បីសម្រេចបាននូវចក្ខុវិស័យនេះ - ភាពជាពលរដ្ឋ សមភាព ការងារ និងការប្រើប្រាស់ NDIS ឲ្យអស់ពីលទ្ធភាព។

មហិច្ឆតារបស់យើងគឺច្បាស់លាស់ណាស់។

យើងចង់បានរដ្ឋវិចតូរីយ៉ាដែលល្អប្រសើរសម្រាប់ជនពិការ។

យើងចង់ឲ្យរដ្ឋវិចតូរីយ៉ាក្លាយរដ្ឋមួយដែលឈានមុខគេទូទាំងប្រទេស ក្នុងការទទួលស្គាល់សេចក្តីប្រាថ្នារបស់ពលរដ្ឋ សេចក្តីប្រាថ្នាផ្នែកសង្គម និងសេដ្ឋកិច្ចរបស់ជនពិការ។

យើងក៏បានប្តេជ្ញាចិត្តផងដែរដើម្បីដោះស្រាយទម្លាប់នៃការរំលោភបំពានដែលជនពិការបានជួបប្រទះ ដែលយើងបានមើលឃើញជនពិការទទួលរងប៉ះពាល់តាមរយៈការស៊ើបអង្កេតថ្មីៗនេះ អំពីអំពើហិង្សាក្នុងគ្រួសារដោយមន្ត្រីដោះស្រាយពាក្យបណ្តឹងពលរដ្ឋ រដ្ឋសភា និងរាជគណៈកម្មការ។

ផែនការពិការភាពនៃរដ្ឋវិចតូរីយ៉ា ឆ្នាំ២០១៧-២០២០ នឹងត្រូវបានលេចឡើងជារូបរាងតាមរយៈការផ្តល់មតិ និងគំនិតរបស់អ្នក។ ខ្ញុំសូមជំរុញលើកទឹកចិត្តជនពិការ និងជនគ្មានពិការភាពវិចតូរីយ៉ាទាំងអស់ ចូលរួមក្នុងកិច្ចសន្ទនាដ៏សំខាន់នេះ។ ចាប់ពីពេលនេះ រហូតដល់ឆ្នាំ២០២០ យើងត្រូវធ្វើការរួមគ្នាដើម្បីទទួលបាននូវកម្លាំងចលករជំរុញកំណើនសេដ្ឋកិច្ច និងសង្គមសម្រាប់ប្រជាពលរដ្ឋវិចតូរីយ៉ាដែលជាជនពិការ - បន្ទាប់មក រក្សាសន្ទុះកំណើននោះដើម្បីសម្រេចបាននូវការផ្លាស់ប្តូរពិតប្រាកដ។

ឥឡូវនេះ គឺដល់ពេលដែលយើងត្រូវអនុវត្តសកម្មភាពនេះហើយ។ យើងមិនអាចធ្វើកិច្ចការនេះបានដោយគ្មានអ្នកបានទេ។



**លោក Martin Foley សមាជិកសភា**
រដ្ឋមន្ត្រីក្រសួងលំនៅដ្ឋាន ពិការភាព និងភាពចាស់ជរា

# ជួយធ្វើឲ្យផែនការពិការភាពរបស់រដ្ឋបន្ទាប់លេចចេញជារូបរាង

ក្នុងអំឡុងឆ្នាំ២០១៥ យើងបានចាប់ផ្តើមដំណើរការនៃការអភិវឌ្ឍន៍ផែនការពិការភាពរបស់រដ្ឋ ឆ្នាំ២០១៧-២០២០។ យើងបានជួបជាមួយជនពិការជាង២០០នាក់ បានធ្វើការពិភាក្សាជុំវិញតុមូលជាមួយស្ថាប័នកំពូល អាជ្ញាធរស្របច្បាប់ និងអង្គការគាំទ្រមតិ ហើយបានធ្វើការជាមួយក្រុមប្រឹក្សាពិការភាពរដ្ឋវិចតូរីយ៉ា ដើម្បីចម្រាញ់យកសំណើ៤២ ពីអាជ្ញាធររដ្ឋាភិបាលក្នុងតំបន់។ យើងបានធ្វើការវិភាគមតិពីជនពិការ៧៧៥នាក់ ជាផ្នែកមួយនៃកម្រងសំណួរ ប្រចាំប្រាំមួយខែនៃផែនការពិការភាពរបស់រដ្ឋ ឆ្នាំ២០១៣-២០១៦។

កម្រងសំណួរនេះបានប្រាប់យើងយ៉ាងច្រើន អំពីអ្វីដែលមានសារសំខាន់ចំពោះជនពិការ។ ក្នុងចំណោមរឿងរ៉ាវផ្ទាល់ខ្លួន គំនិត និងបញ្ហាជាច្រើន ប្រធានបទសំខាន់មួយចំនួនបានលេចឡើង រួមមាន៖

- ការមិនអាចចូលទៅកាន់ទីបរិស្ថាន សំណង់ ប្រព័ន្ធ និងសេវាកម្ម បន្តរាំងមនុស្សមិនឲ្យចូលរួមក្នុងសហគមន៍
- ឥរិយាបថអវិជ្ជមានចំពោះសហគមន៍ មានផលប៉ះពាល់ធ្ងន់ធ្ងរ និងរាលដាលទៅលើជីវិតមនុស្ស
- ជនពិការនៅតែបន្តការតស៊ូដើម្បីមានភាពឯករាជ្យ ហើយមានមតិកាន់តែច្រើនអំពីជីវិត និងអ្វីៗដែលមានសារៈសំខាន់ចំពោះពួកគេ
- ការចូលរួមផ្នែកសេដ្ឋកិច្ចគឺមានសារៈសំខាន់ - សម្រាប់អត្តសញ្ញាណ សន្តិសុខ និងការដាក់បញ្ចូលទៅក្នុងសង្គម
- មានតម្រូវការទទួលខុសត្រូវកាន់តែច្រើន រួមទាំងវិធាន និងគោលដៅដើម្បីជំរុញឲ្យមានការផ្លាស់ប្តូរ។

ព័ត៌មាននេះរួមជាមួយនឹងការពិគ្រោះយោបល់ របាយការណ៍ ការស្ទង់មតិ និងការស្រាវជ្រាវពីមុន បានផ្តល់ជាមូលដ្ឋានសម្រាប់ឯកសារពីរ៖

- ឯកសារពិភាក្សានេះ
- ឯកសារអម ជាមួយនឹងឯកសារពិភាក្សាផែនការពិការភាពនៃរដ្ឋវិចតូរីយ៉ា ឆ្នាំ២០១៧-២០២០ ដែលផ្តល់ព័ត៌មាន និងភស្តុតាងយ៉ាងលម្អិតអំពីប្រធានបទដែលបានកំណត់។

ក្នុងអំឡុងឆ្នាំ២០១៦ រដ្ឋាភិបាលចង់ដឹងឮពីសមាជិកសាធារណៈជន - រួមទាំងជនពិការ អ្នកថែទាំ និងជនគ្មានពិការភាព - អំពីចំណាត់ការដែលពួកគេជឿថា រដ្ឋវិចតូរីយ៉ាគួរតែចាត់វិធានការ។

ឯកសារពិភាក្សា ឯកសារអម និងឯកសារជាច្រើនផ្សេងទៀត ដែលជួយអ្នក ដើម្បីផ្តល់នូវមតិដល់យើង តាមរយៈវ៉ិបសាយ៖
www.statedisabilityplan.vic.gov.au

ថ្ងៃបើក និងបិទការទទួលមតិមានផ្តល់នៅតាមវ៉ិបសាយ៖
www.statedisabilityplan.vic.gov.au

**វ៉ិបសាយ៖** តាមរយៈវ៉ិបសាយពិគ្រោះយោបល់៖
www.statedisabilityplan.vic.gov.au

**ផ្ញើតាមប្រៃសណីយ៍៖** Victorian state disability plan 2017–2020,
Office for Disability
Department of Health and Human Services
50 Lonsdale Street
GPO Box 4057, Melbourne 3000

**អ៊ីម៉ែល៖** statedisabilityplan@dhhs.vic.gov.au

**ទូរស័ព្ទ៖** 1300 880 043

TTY/ទូរស័ព្ទជាសម្លេង – 133 677
បន្ទាប់មកស្នើសុំលេខ 1300 880 043

ទូរស័ព្ទនិយាយ និងស្តាប់ (Speak and Listen)
– 1300 555 727 បន្ទាប់មកស្នើសុំលេខ
1300 880 043

រាល់មតិទាំងអស់នឹងជួយធ្វើឲ្យលេចជារូបរាងឡើង នូវកំណែចុងក្រោយនៃផែនការពិការភាពរដ្ឋវិចតូរីយ៉ា ឆ្នាំ២០១៧-២០២០ ដែលនឹងចូលជាធរមាននៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៧។

# មាតិការឿង


| | |
|---|---|
| អារម្ភកថា | iii |
| ជួយធ្វើឲ្យផែនការពិការភាពរបស់រដ្ឋបន្ទាប់ លេចចេញជារូបរាង | iv |
| សេចក្តីផ្តើម | 1 |
| តើឯកសារពិភាក្សានេះផ្តោតលើអ្វីខ្លះ? | 2 |
| ប្រធានបទទី១៖ ភាពជាពលរដ្ឋសកម្ម | 3 |
| ប្រធានបទទី២៖ សិទ្ធិ និងសមភាព | 7 |
| ប្រធានបទទី៣៖ ការចូលរួមក្នុងវិស័យសេដ្ឋកិច្ច | 11 |
| ប្រធានបទទី៤៖ ការប្រើប្រាស់ NDIS ឲ្យអស់ពីលទ្ធភាព | 15 |
| ការជំរុញឲ្យមានលទ្ធផល | 19 |
| សេចក្តីសន្និដ្ឋាន | 22 |

# សេចក្តីផ្តើម

ពលរដ្ឋម្នាក់ ក្នុងចំណោមពលរដ្ឋវិចតូរីយ៉ាប្រាំនាក់ គឺជាជនពិការ។

ពលរដ្ឋម្នាក់ៗ ក្នុងចំណោមពលរដ្ឋវិចតូរីយ៉ាទាំងនេះ នឹងមានបទពិសោធន៍ផ្នែកពិការភាពតាមវិធីផ្សេងៗគ្នា អាស្រ័យលើស្ថានភាពបុគ្គល បទពិសោធន៍ជីវិត ចរិត ភាពធ្ងន់ធ្ងរនៃការចុះខ្សោយរាងកាយ ហើយនិងតម្រូវការ និងសមត្ថភាពរបស់ពួកគេ។

លើសពីនេះទៀត បទពិសោធន៍របស់ពួកគេផ្នែកពិការភាពត្រូវបានបង្កើតឡើងតាមរយៈឧបសគ្គផ្នែកសង្គម វប្បធម៌ ការអប់រំ សេដ្ឋកិច្ច និងបរិស្ថានដែលពួកគេជួបប្រទះជារៀងរាល់ថ្ងៃ។ ជនពិការក៏អាចមានគុណវិបត្តិបន្ថែមទៀតដែរដោយផ្អែកលើភេទ អាយុ សាវតារប្បធម៌ ឬសាសនា ភាពជាជនជាតិដើម ទំនោរផ្លូវភេទ និងស្ថានភាពសេដ្ឋកិច្ចសង្គម។

ខណៈដែលលក្ខណៈ និងកម្រិតនៃគុណវិបត្តិនេះប្រែប្រួលពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតក្តី ពលរដ្ឋវិចតូរីយ៉ាដែលជាជនពិការទំនងជាជួបប្រទះនឹងការប្រកាន់រើសអើង និងការមាក់ងាយ ការរស់នៅក្នុងភាពក្រីក្រ មានសុខភាពទន់ខ្សោយ កម្រិតទាបនៃការទទួលបានការអប់រំ ហើយពុំមានការងារធ្វើ។ [1]

ឯកសារពិភាក្សានេះ រាប់បញ្ចូលប្រជាពលរដ្ឋវិចតូរីយ៉ាទាំងអស់ដែលជាជនពិការ ហើយគំនិតនៅពីក្រោយនោះគឺមានលក្ខណៈសាមញ្ញ៖ យើងត្រូវធ្វើការឲ្យបានច្រើនបន្ថែមទៀតសម្រាប់ជនពិការ ដើម្បីដាក់បញ្ចូលជនពិការទៅក្នុងសហគមន៍រដ្ឋវិចតូរីយ៉ាទាំងស្រុង។ សេចក្តីប្រាថ្នារបស់យើងគឺធ្វើឲ្យរដ្ឋវិចតូរីយ៉ាក្លាយជារដ្ឋឈានមុខគេទូទាំងប្រទេសនៅក្នុងផ្នែកនេះ។

រដ្ឋវិចតូរីយ៉ាកំពុងពង្រីកជាបន្តបន្ទាប់ ដើម្បីបង្កើតនូវគម្រោងធានារ៉ាប់រងជាតិសម្រាប់ជនពិការភាព (NDIS)។ ប្រទេសអូស្ត្រាលីគឺជាប្រទេសហត្ថលេខី នៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិរបស់ជនពិការ **សហព័ន្ធរបស់យើងមានច្បាប់ប្រកាន់រើសអើងជនពិការសហព័ន្ធ ឆ្នាំ១៩៩២** និងយុទ្ធសាស្ត្រជនពិការភាពជាតិ ឆ្នាំ២០១០-២០២០ និងនៅកម្រិតថ្នាក់រដ្ឋ យើងមាន**ច្បាប់ពិការភាព ឆ្នាំ២០០៦, ច្បាប់ធម្មនុញ្ញសិទ្ធិមនុស្ស និងការទទួលខុសត្រូវនៃរដ្ឋវិចតូរីយ៉ា ឆ្នាំ២០០៦** និង **ច្បាប់ឱកាសស្មើភាពគ្នានៃរដ្ឋវិចតូរីយ៉ា ឆ្នាំ២០១០**។

ផែនការពិការភាពពីមុនរបស់រដ្ឋវិចតូរីយ៉ាចំនួនពីរ បានឈានមុខគេក្នុងការរិះរកវិធីថ្មីនៃការគិតពិចារណាអំពីពិការភាព ដែលជំរុញដោយការប្តេជ្ញាចិត្តចំពោះសិទ្ធិមនុស្ស ហើយផ្តោតលើការបង្កើនជម្រើសបុគ្គល និងការត្រួតពិនិត្យ និងការដាក់បញ្ចូលក្នុងសហគមន៍។ នេះគឺជាគំនិតសំខាន់បំផុតនៃ NDIS ដែលត្រូវបានកំណត់ថានឹងអនុវត្តយ៉ាងពេញលេញនៅឆ្នាំ២០២០។

NDIS គឺជាកំណែទម្រង់កើតមានតែម្តងក្នុងមួយជំនាន់ ដែលនឹងអនុញ្ញាតឲ្យជនពិការប្រហែលជា១០៥,000 នាក់ក្នុងរដ្ឋវិចតូរីយ៉ាទទួលបានការគាំទ្រដែលពួកគេត្រូវការ ដើម្បីដឹកនាំជីវិតពេញលេញ ហើយសកម្ម - ដូចជាទៅសាលារៀន វិទ្យាស្ថាន TAFE ឬសាកលវិទ្យាល័យ ទទួលបានការងារធ្វើ និងការចូលរួមក្នុងសហគមន៍។ ក៏ប៉ុន្តែកិច្ចការនេះត្រូវតែសម្រេចបានតាមរយៈការធ្វើកំណែទម្រង់ទូលំទូលាយ។ យើងក៏ត្រូវធានាដែរថា សេវាកម្មចម្បងរបស់យើង - ហើយជាទូទៅ សហគមន៍រដ្ឋវិចតូរីយ៉ា - គឺជាសហគមន៍ដែលអាចចូលបាន និងអាចដាក់បញ្ចូលដើម្បីឲ្យជនពិការទាំងអស់ មានឱកាសដូចគ្នានឹងពលរដ្ឋផ្សេងទៀត។

ការស៊ើបអង្កេតដោយរដ្ឋសភា អំពីការដាក់បញ្ចូលទៅក្នុងសង្គម និងពលរដ្ឋវិចតូរីយ៉ាដែលមានពិការភាព បានយល់ពីអ្វីដែលយើងដឹងរួចទៅហើយ - ទោះបីជាការពិតដែលថា ពលរដ្ឋរដ្ឋវិចតូរីយ៉ាដែលមានពិការភាព មានសិទ្ធិដូចគ្នានឹងពលរដ្ឋក្នុងរដ្ឋតែមួយក៏ដោយ ពួកគេជាញឹកញាប់ប្រឈមនឹងឧបសគ្គចម្បងក្នុងការចូលរួមនៅក្នុងជីវិតសង្គម សេដ្ឋកិច្ច និងភាពជាពលរដ្ឋ ដូច្នេះហើយមិនអាចសម្រេចបាននូវសក្តានុពលពេញលេញរបស់ពួកគេឡើយ។ ពួកគេជាញឹកញាប់ ស្ថិតនៅចុងភាពលំអៀងនៃការដឹងខ្លួន និងមិនដឹងខ្លួន ដែលក្នុងនោះការសន្មត់មិនត្រឹមត្រូវបានធ្វើឡើងអំពីអ្វីដែលពួកគេអាចធ្វើបាន និងមិនអាចធ្វើបាន។

វាជាតម្រូវការជាចាំបាច់ដើម្បីធ្វើឲ្យបានល្អប្រសើរ សម្រាប់ពលរដ្ឋវិចតូរីយ៉ាទាំងអស់ដែលមានពិការភាព។

វាជាការទទួលខុសត្រូវដែលយើងទាំងអស់គ្នាចែករំលែក - រដ្ឋាភិបាល អាជីវកម្ម សហគមន៍ និងបុគ្គល។

1 ក្រសួងសុខាភិបាល និងសេវាមនុស្សសាស្ត្រ ឆ្នាំ២០១៦, *ឯកសារអមជាមួយឯកសារពិភាក្សាផែនការពិការភាពនៃរដ្ឋវិចតូរីយ៉ា ឆ្នាំ ២០១៧-២០២០*, រដ្ឋាភិបាលវិចតូរីយ៉ា ទីក្រុងមែលប៊ន។

# តើឯកសារពិភាក្សានេះផ្ដោតលើអ្វីខ្លះ?

ឯកសារពិភាក្សានេះផ្ដោតលើប្រធានបទបួន។ ប្រធានបទទាំងបួននេះមាន៖

- ភាពជាពលរដ្ឋសកម្ម
- សិទ្ធិ និងសមភាព
- ការចូលរួមផ្នែកសេដ្ឋកិច្ច
- ការប្រើប្រាស់គម្រោង NDIS ឲ្យអស់ពីលទ្ធភាព។

ផែនការពិការភាពនៃរដ្ឋវិចតូរីយ៉ា ឆ្នាំ២០១៧-២០២០ នឹងផ្ដោតយ៉ាងច្បាស់លើលទ្ធផលដែលអាចវាស់ស្ទង់បាន ហើយដែលមានការព្រមព្រៀងគ្នា ។

ដោយមានការនេះនៅក្នុងគំនិត ឯកសារពិភាក្សានេះពិនិត្យមើលអ្វីដែលយើងត្រូវធ្វើការខុសៗគ្នា ដើម្បីជំរុញឲ្យមានលទ្ធផលដែលនឹងធ្វើឲ្យមានការផ្លាស់ប្ដូរជាក់ស្ដែង ក្នុងជីវិតរស់នៅរបស់ជនពិការភាព។

ឯកសារពិភាក្សានេះត្រូវបានរៀបចំឡើង ក្នុងគោលបំណងដើម្បីបន្តកិច្ចសន្ទនាដែលបានចាប់ផ្ដើមនៅឆ្នាំ២០១៥។ គំនិតមួយចំនួនដើម្បីចាត់ចំណាត់ការ ត្រូវបានដាក់បញ្ចូលនៅក្រោមប្រធានបទនីមួយៗ ក៏ប៉ុន្តែយើងចង់ឮពីអ្វីដែលមានសារសំខាន់ចំពោះអ្នក - អ្វីដែលនឹងធ្វើឲ្យមានការផ្លាស់ប្ដូរច្រើនបំផុតនៅក្នុងជីវិតរបស់អ្នក - និងអ្វីដែលរដ្ឋាភិបាល អាជីវកម្ម និងសហគមន៍ អាចធ្វើបានដើម្បីជួយឲ្យរឿងនេះកើតមានឡើង។

ដើម្បីជួយអ្នកក្នុងការឆ្លើយតបទៅនឹងឯកសារនេះ យើងបានដាក់បញ្ចូលសំណួរបី ឬបួននៅចុងបញ្ចប់នៃប្រធានបទនីមួយៗ និងនៅចុងបញ្ចប់នៃផ្នែក “ការជំរុញឲ្យមានលទ្ធផល” ក្នុងឯកសារនេះដើម្បីជំរុញឲ្យអ្នកគិត។ ប្រធានបទនីមួយៗមានសំណួរខុសគ្នាបន្តិច ក៏ប៉ុន្តែសំណួរទាំងនេះសួរថា៖

- តើការផ្លាស់ប្ដូរអ្វីខ្លះនឹងមានសារៈសំខាន់ចំពោះអ្នក?
- តើយើងគួរតែវាស់ស្ទង់ដំណើរការរីកចំរើនដោយរបៀបណា?
- តើរដ្ឋាភិបាលអាចធ្វើអ្វីខ្លះ ដើម្បីធ្វើឲ្យមានការផ្លាស់ប្ដូរពិតប្រាកដនៅក្នុងផ្នែកនេះ?
- តើសហគមន៍ និងវិស័យអាជីវកម្មអាចធ្វើអ្វីខ្លះ ដើម្បីធ្វើឲ្យមានការផ្លាស់ប្ដូរពិតប្រាកដនៅក្នុងផ្នែកនេះ?

យើងក៏ចង់ដឹងផងដែរ ថាតើអ្នកគិតយ៉ាងណាដែរ ថាប្រធានបទធំៗទាំងបួននេះ ចាប់យកបញ្ហាដែលមានសារៈសំខាន់បំផុតចំពោះអ្នក ហើយផ្ដល់នូវក្របខ័ណ្ឌត្រឹមត្រូវសម្រាប់ផែនការពិការភាពរដ្ឋវិចតូរីយ៉ា។

មតិរបស់អ្នកនឹងជួយធ្វើឲ្យផែនការចុងក្រោយនេះចេញជារូបរាង។

# ប្រធានបទទី១៖
# ភាពជាពលរដ្ឋសកម្ម

... ដោយហេតុថា ជនពិការគួរតែអាច
ចូលរួមក្នុងជីវិតសហគមន៍ និងជីវិត
រស់នៅជាពលរដ្ឋ

តិចជាង

## ១ភាគរយ

សមាជិកទីប្រឹក្សា និងគណៈកម្មការវិស័យសាធារណៈ គឺជាជនពិការ។[2]

## ៦៨ភាគរយ

នៃប្រជាជនដែលមានពិការភាពចូលរួមក្នុងកីឡា។

## ៧៩ភាគរយ

នៃប្រជាជនដែលគ្មានពិការភាព ចូលរួមក្នុងកីឡា។[3]

‘ប្រសិនបើមនុស្សថ្លង់ចង់ក្លាយជាសមាជិកក្រុមប្រឹក្សាសម្រាប់អង្គការសហគមន៍ ឬអង្គការកីឡា វាមិនទំនងខ្លាំងណាស់ដែលថាអង្គការនេះនឹងបង់ប្រាក់សម្រាប់តម្រូវការចូលរួម ដូចជាអ្នកបកប្រែផ្ទាល់មាត់ ឬអ្នកកត់ត្រា ដើម្បីជួយសម្រួលការចូលរួមរបស់ពួកគេនោះឡើយ។“

*របាយការណ៍ស៊ើបអង្កេតអំពីការដាក់បញ្ចូលទៅក្នុងសង្គម*

មានតែ

## ៦ភាគរយ

នៃតំណាងរដ្ឋាភិបាលក្នុងតំបន់ គឺជាជនពិការ។[4]

2 ក្រសួងសុខាភិបាល និងសេវាមនុស្សធម៌ ឆ្នាំ២០១៦, *ឯកសារអមជាមួយឯកសារពិភាក្សាផែនការពិការភាពរដ្ឋវិចតូរីយ៉ា ឆ្នាំ២០១៧-២០២០*, រដ្ឋាភិបាលវិចតូរីយ៉ា ទីក្រុងម៉េលប៊ន ទំព័រ 9។

3 Ibid.

4 Ibid,. ទំព័រ 10។

# ប្រធានបទទី១៖
# ភាពជាពលរដ្ឋសកម្ម

## ប្រការសំខាន់ៗដែលត្រូវដឹង

- ការចូលរួមទាន់ពេលជាមួយជនពិការ ពង្រឹងផ្នត់គំនិតថា ការចូលរួមរបស់ពលរដ្ឋ និងការដាក់បញ្ចូលទៅក្នុងសង្គម គឺជាបញ្ហាពីរសំខាន់បំផុតសម្រាប់ពួកគេ។
- មានជនពិការតិចតួចណាស់នៅក្នុងតួនាទីនយោបាយ ដែលឈរឈ្មោះជាតំណាងរាស្ត្រ និងតួនាទីផ្សេងទៀត នៅក្នុងសហគមន៍ រួមទាំងមុខតំណែងគណៈកម្មការគ្រប់គ្រង និងទីប្រឹក្សា។
- នៅពេលគិតអំពីការចូលរួមក្នុងសង្គម ជនពិការជាញឹកញាប់មិនទទួលបានឱកាសសោះឡើយ។ តិចជាងមួយភាគបីនៃជនពិការ (៣១ភាគរយ) ក្នុងរដ្ឋវិចតូរីយ៉ា បានចូលរួមយ៉ាងសកម្មនៅក្នុងក្រុមសហគមន៍ បើប្រៀបធៀបជាមួយនឹងប្រមាណជា៣៦ភាគរយនៃចំនួនប្រជាជនសរុប។
- ក្នុងការសិក្សាមួយដែលធ្វើឡើងដោយសាកលវិទ្យាល័យ Deakin មានតែប្រាំបួនភាគរយនៃជនពិការប៉ុណ្ណោះ បាននិយាយថាតម្រូវការទំនាក់ទំនងសង្គមរបស់ពួកគេត្រូវបានបំពេញទាំងស្រុង ហើយមានតែប្រាំមួយភាគរយប៉ុណ្ណោះបាននិយាយថា តម្រូវការចូលរួមក្នុងសហគមន៍របស់ពួកគេត្រូវបានបំពេញទាំងស្រុង។
- ការស៊ើបអង្កេតដោយរដ្ឋសភា លើការដាក់បញ្ចូលទៅក្នុងសង្គម និងជនពិការក្នុងរដ្ឋវិចតូរីយ៉ាបានយល់ឃើញថាខណៈដែលបរិបទចម្បងត្រូវបានចាត់ទុកថាស័ក្តិសមសម្រាប់ការពង្រឹងកម្មសិទ្ធិ និងការដាក់បញ្ចូលទៅក្នុងសង្គមភាគច្រើន គឺមិនមានលក្ខណៈបញ្ចូលគ្នាទាំងស្រុងនោះទេ។

ចំពោះព័ត៌មានបន្ថែម សូមមើលឯកសារអមនេះ។

ប្រជាពលរដ្ឋវិចតូរីយ៉ាដែលជាជនពិការ គួរតែជាអ្នកចូលរួមយ៉ាងសកម្មនៅក្នុងជីវិតក្នុងរដ្ឋរបស់ខ្លួន។

រដ្ឋវិចតូរីយ៉ាបានធ្វើការវាយលុកយ៉ាងសំខាន់មួយចំនួន ក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយ ឬច្រើនជាងនេះ។ យើងមានវិស័យស្ម័គ្រចិត្តដែលបានគាំទ្រយ៉ាងរស់រវើក។ យើងមានក្រុមប្រឹក្សាពិការភាពរដ្ឋវិចតូរីយ៉ា ដែលបានបង្កើតឡើងដោយមានសមាសភាពជនពិការ និងអ្នកថែទាំ ដើម្បីណែនាំរដ្ឋាភិបាលលើបញ្ហាពិការភាព។ ក្រុមប្រឹក្សាណែនាំស្តីពីពិការភាពជាច្រើន ប្រតិបត្តិការតាមកម្រិតក្នុងតំបន់។ ក៏ប៉ុន្តែ នៅតែមានផ្លូវវែងឆ្ងាយទៀតដែលត្រូវទៅ។

ប្រហែល២០ភាគរយនៃពលរដ្ឋវិចតូរីយ៉ាទាំងអស់ គឺជាជនពិការ។[5] ការនេះផ្តល់អត្ថន័យដើម្បីធានាឲ្យមានតម្រូវការ និងបទពិសោធន៍នៃផ្នែកសហគមន៍របស់យើងដ៏ធំនេះ ដែលត្រូវបានដាក់បញ្ចូលក្នុងកិច្ចជជែកពិភាក្សាជាសាធារណៈ និងវេទិកាស្តីពីការធ្វើការសម្រេចចិត្ត។ ក្នុងចំណោមកិច្ចការជាច្រើន នេះមានន័យថាការកែលម្អលទ្ធភាព និងវិធីនៃការប្រាស្រ័យទាក់ទងដែលអាចឲ្យមនុស្សទាំងអស់មានមតិ រួមទាំងការបោះឆ្នោត។ វាជាផលប្រយោជន៍របស់អ្នករាល់គ្នា ដើម្បីជនពិការបញ្ចេញមតិដោយផ្ទាល់ខ្លួន ជាជាងឲ្យគេនិយាយជំនួស ឬទុកចោលជនពិការទាំងស្រុង។ យោងតាមពាក្យសម្តីរបស់ជនពិការជាច្រើននាក់ បានឲ្យដឹងថា៖ ‘ គួរតែគ្មានអ្វីសោះអំពីយើង ដោយគ្មានពួកយើងទេនោះ “។

ការភ្ជាប់ទំនាក់ទំនង និងការយល់ពីកម្មសិទ្ធិ គឺជាមូលដ្ឋានគ្រឹះចម្បងនៃបទពិសោធន៍របស់មនុស្សគ្រប់រូប ក្នុងការរស់នៅក្នុងជីវភាពពេញលេញ និងជាទីគាប់ចិត្ត។ មិនត្រឹមតែប៉ុណ្ណោះសោត ក្នុងនាមជាសហគមន៍មួយ យើងទទួលបានអត្ថប្រយោជន៍យ៉ាងច្រើនពីភាពចម្រុះ និងភាពសម្បូរបែបនៃគំនិត បទពិសោធន៍ និងចំណេះដឹងដែលជនពិការនាំមកក្នុងជីវិតវប្បធម៌ កីឡា សង្គម និងភាពជាពលរដ្ឋ។ ការដាក់បញ្ចូលឱកាសសម្រាប់ជនពិការដើម្បីចូលរួមក្នុងសកម្មភាពកីឡាសំខាន់ៗ និងក្លឹបកីឡា នាំឲ្យមានការកើនឡើងនូវការចូលរួមទាំងក្នុងសង្គម និងភាពជាពលរដ្ឋ ហើយជួយទម្លុះឧបសគ្គឥរិយាបទអវិជ្ជមាន។[6]

5 ក្រសួងសុខាភិបាល និងសេវាមនុស្សសាស្ត្រ ឆ្នាំ២០១៦, *ឯកសារអមជាមួយឯកសារពិភាក្សាផែនការពិការភាពនៃរដ្ឋវិចតូរីយ៉ា ឆ្នាំ២០១៧-២០២០*, រដ្ឋាភិបាលវិចតូរីយ៉ា ទីក្រុងមែលប៊ន ទំព័រ 21

6 Ibid., ទំព័រ 9។

យើងចាំបាច់ត្រូវគាំទ្រសមាជិកទាំងអស់ក្នុងសហគមន៍ ដើម្បីទទួលបានការចូលរួម និងរួមចំណែក - ក្នុងនាមជាអ្នកចូលរួមយ៉ាងសកម្ម អ្នកធ្វើការសម្រេចចិត្ត អ្នកដឹកនាំ អ្នកទស្សនា និងអ្នកស្ម័គ្រចិត្ត។

**គំនិតមួយចំនួនអំពីកិច្ចការសំខាន់ៗ ដែលអាចធ្វើឡើងក្នុងរយៈពេលបួនឆ្នាំបន្ទាប់ រួមមាន៖**

- ការបង្កើននូវការចូលរួមយ៉ាងសកម្មរបស់ជនពិការ ក្នុងទីប្រឹក្សា និងគណៈកម្មការ
- ការបង្កើននូវសក្តានុពលភាពនៃការដឹកនាំរបស់ជនពិការ និងការផ្តល់នូវផ្លូវលំ សម្រាប់អ្នកដឹកនាំជាជនពិការដែលមហិច្ឆតា
- ការបង្កើតឱកាសបន្ថែមទៀតសម្រាប់ជនពិការឲ្យមានសំឡេងតំណាងឲ្យផលប្រយោជន៍របស់ខ្លួន និងដាក់ឥទ្ធិពលលើទិសដៅរបស់រដ្ឋាភិបាល
- ការបង្កើតផ្លូវលំថ្មី និងឱកាសសម្រាប់ជនពិការ ដើម្បីចូលរួមក្នុងក្លឹបវប្បធម៌ និងសង្គម
- ការកសាងសមត្ថភាពនៃច្បាប់ក្រុមកីឡា រួមជាមួយនឹងក្លឹបកីឡា និងការកម្សាន្តក្នុងតំបន់ដើម្បីដាក់បញ្ចូលជនពិការ។

## សំណួរ៖

- ក្នុងនាមជាបុគ្គល តើអ្វីដែលនឹងធ្វើឲ្យមានការផ្លាស់ប្តូរខ្លាំងបំផុតចំពោះអ្នកនៅក្នុងតំបន់នេះ?
- តើយើងគួរតែវាស់ស្ទង់ដំណើរការរីកចំរើនដោយរបៀបណា?
- តើរដ្ឋាភិបាលអាចធ្វើអ្វីខ្លះ ដើម្បីធ្វើឲ្យមានការផ្លាស់ប្តូរពិតប្រាកដនៅក្នុងផ្នែកនេះ?
- តើសហគមន៍ និងវិស័យអាជីវកម្មអាចធ្វើអ្វីខ្លះ ដើម្បីធ្វើឲ្យមានការផ្លាស់ប្តូរពិតប្រាកដនៅក្នុងផ្នែកនេះ?

# ប្រធានបទទី២៖
# សិទ្ធិ និងសមភាព

... ការការពារ និងការលើកកម្ពស់សិទ្ធិ
និងការទទួលបានឱកាសស្មើភាពគ្នា

ការប្រកាន់រើសអើងជនពិការ បានក្លាយជាមូលហេតុធំជាងគេតែមួយគត់នៃពាក្យបណ្តឹងទៅកាន់ VEOHRC សម្រាប់រយៈពេលប្រាំឆ្នាំចុងក្រោយនេះ។[7]



ស្មើរតែ

**១នាក់ ក្នុងចំណោម៤នាក់**

ស្ត្រី និងក្មេងស្រីពិការបួននាក់ត្រូវបានគេរាយការណ៍ថា ជាជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ។[8]



**៩៥ភាគរយ**

នៃជនពិការរស់នៅក្នុងភាពក្រីក្រ ឬក្បែរនឹងភាពក្រីក្រ។[9]




ជនពិការទំនងជា

**៦ដង**

ដែលជួលផ្ទះពីអាជ្ញាធរលំនៅដ្ឋានរដ្ឋ។[10]

7 ក្រសួងសុខាភិបាល និងសេវាមនុស្សសាស្រ្ត ឆ្នាំ២០១៦, *ឯកសារអមជាមួយឯកសារពិភាក្សាផែនការពិការភាពនៃរដ្ឋវិចតូរីយ៉ា ឆ្នាំ២០១៧-២០២០*, រដ្ឋាភិបាលវិចតូរីយ៉ា ទីក្រុងមែលប៊ន ទំព័ 11។

8 Ibid,. ទំព័រ 13។

9 Ibid,. ទំព័រ 11។

10 Ibid,. ទំព័រ 15។

# ប្រធានបទទី២៖ សិទ្ធិ និងសមភាព

## ប្រការសំខាន់ៗដែលត្រូវដឹង

- ជនពិការជួបប្រទះនឹងការប្រកាន់រើសអើង គុណវិបត្តិ និងវិសមភាពច្រើនគួរឲ្យកត់សម្គាល់។ ក្នុងឆ្នាំ ២០១៤-២០១៥ ការប្រកាន់រើសអើងជនពិការ បានធ្វើឲ្យមានការដាក់ពាក្យបណ្ដឹងមួយភាគបួននៃពាក្យបណ្ដឹងទាំងអស់ ទៅកាន់គណៈកម្មការរដ្ឋវិចតូរីយ៉ាស្ដីពីឱកាសស្មើភាពគ្នា និងសិទ្ធិមនុស្ស។ លើសពីនេះទៅទៀត ចំនួនពាក្យបណ្ដឹងបានកើនឡើងដល់ទៅ១០ភាគរយ ក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ។
- ជាងប្រាំមួយភាគរយនៃជនពិការក្នុងរដ្ឋវិចតូរីយ៉ា ជួលលំនៅដ្ឋានរដ្ឋ ឬលំនៅដ្ឋានសង្គម បើប្រៀបធៀបទៅនឹងមួយភាគរយនៃជនគ្មានពិការភាព។
- ជនពិការរាយការណ៍អំពីលទ្ធផលសុខភាព អន់ជាងជនគ្មានពិការភាព ហើយពួកគេរាយការណ៍ថា អ្នកផ្ដល់សេវាសុខភាពមួយចំនួនមិនមានបរិក្ខារ ឬចំណេះដឹងសមស្របដើម្បីផ្ដល់នូវសេវាដែលពួកគេស្វែងរក។
- វិសមភាពនៃការទទួលបានសេវាដឹកជញ្ជូន គឺជាឧបសគ្គមួយសម្រាប់ជនពិការភាគច្រើន។ ការមិនដាក់បញ្ចូលទំនងជាអាចកើតមានឡើង គួបផ្សំបន្ថែមនៅក្នុងតំបន់ និងតំបន់ដាច់ស្រយាល។
- រាជគណៈកម្មការទទូលបន្ទុកករណីអំពើហិង្សាក្នុងគ្រួសារ បានរកឃើញថា ម្នាក់ក្នុងចំណោមស្ត្រី និងក្មេងស្រីពិការបួននាក់ ត្រូវបានគេរាយការណ៍ថាជាជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ។
- រាជគណៈកម្មការបានរកឃើញថា ស្ត្រីពិការបានប្រទះអំពើហិង្សាគ្រប់ប្រភេទ ក្នុងអត្រាខ្ពស់ជាងមុនបាន បង្កើនភាពធ្ងន់ធ្ងរ និងរយៈពេលយូរជាងស្ត្រីផ្សេងទៀត។

សម្រាប់ព័ត៌មានបន្ថែម សូមមើលឯកសារអម។

ពលរដ្ឋវិចតូរីយ៉ាបានប្ដេជ្ញាបង្កើតគោលគំនិតនៃសិទ្ធិជាសកល និងយុត្តិធម៌។

ក៏ប៉ុន្តែនៅមានគម្លាតរវាងអ្វីដែលយើងជឿ និងរបៀបដែលយើងប្រព្រឹត្ត។

ការស៊ើបអង្កេតដោយរដ្ឋសភា លើការដាក់បញ្ចូលទៅក្នុងសង្គម និងពលរដ្ឋវិចតូរីយ៉ាដែលមានពិការភាពបានយល់ឃើញថា ‘ ឥរិយាបថអវិជ្ជមានចំពោះភាពពិការ នៅតែមានក្នុងសហគមន៍ ហើយមានផលវិបាកចំពោះរបៀបដែលគេប្រព្រឹត្ត និងប្រាស្រ័យទាក់ទងជាមួយជនពិការ។ ការរំពឹងទុកកម្រិតទាប ការជៀសវាង ការប្រកាន់រើសអើង និងការប្រទូសរ៉ាយបណ្ដាលឲ្យមានការដកចេញ និងការចូលរួមដោយគ្មានន័យ"។

ការស៊ើបអង្កេតថ្មីៗនេះស្ដីពីការថែរក្សាជនពិការ ដោយមន្ត្រីស៊ើបអង្កេតបណ្ដឹងពលរដ្ឋនៃរដ្ឋវិចតូរីយ៉ា និងរដ្ឋសភា បានលើកឡើងពីការរំលោភបំពានដែលជនពិការបន្តជួបប្រទះ។ ការទទួលរងការរំលោភបំពាន និងការរំលោភសិទ្ធិមនុស្សក៏មានកើតឡើងដែរនៅក្នុងសហគមន៍ទាំងមូល។ ការស៊ើបអង្កេតថ្មីៗនេះដោយរាជគណៈកម្មការលើអំពើហិង្សាក្នុងគ្រួសារ បានកំណត់អំពើហិង្សាក្នុងគ្រួសារជាផ្នែកមួយនៃបញ្ហាធំ និងធ្ងន់ធ្ងរនៃអំពើហិង្សា និងការរំលោភបំពានលើជនពិការ។

បញ្ហាប្រឈមទៅនឹងសិទ្ធិ និងសមភាពត្រូវបានគួបផ្សំជាមួយគុណវិបត្តិ និងការប្រកាន់រើសអើងដែលជនពិការអាចជួបប្រទះផងដែរ ដោយផ្អែកលើភេទ អាយុ លក្ខណៈភេទ ភាពជាជនជាតិដើម សាវតារប្បធម៌ ជំនឿ និងឋានៈជាអ្នកចំណាកស្រុក។ កត្តាទាំងអស់នេះមានឥទ្ធិពលទៅលើរបៀបដែលមនុស្សដឹកនាំជីវិតពីមួយថ្ងៃ ទៅមួយថ្ងៃ និងកម្រិតនៃការដាក់បញ្ចូល ឬការបដិសេធដែលពួកគេបានប្រឈមមុខ។

រួមជាមួយពលរដ្ឋវិចតូរីយ៉ាដទៃទៀតទាំងអស់ ជនពិការប្រើប្រាស់សេវាសាធារណៈជាច្រើនប្រភេទដែលមានផ្ដល់ ហើយចូលរួមប្រើប្រាស់ប្រព័ន្ធជាច្រើនប្រភេទ ជាអកុសល ការពិតប្រចាំថ្ងៃសម្រាប់ជនពិការជាច្រើននាក់ គឺជាផ្នែកមួយនៃសិទ្ធិ មិនស្មើភាពក្នុងការទទួលបានទីកន្លែង សេវាកម្ម និងព័ត៌មាន - សម្រាប់អ្វីៗគ្រប់យ៉ាងចាប់ពីលំនៅដ្ឋាន រហូតដល់ការអប់រំ និងការងារ។ ជនពិការក៏បានជួបប្រទះការប្រព្រឹត្តមិនស្មើភាពគ្នាដែរ នៅទូទាំងប្រព័ន្ធសេវាកម្មសំខាន់ៗជាច្រើន រួមមានសេវាសុខភាព ការដឹកជញ្ជូន និងតុលាការ។

សមភាពទាមទារឲ្យចាត់ចំណាត់ការ ដើម្បីកែប្រែស្ថានភាពនេះ។ ការនេះមានន័យថា ការធ្វើឲ្យសេវាប្រចាំថ្ងៃកាន់តែឆ្លើយតបទៅនឹងតម្រូវការរបស់ជនពិការ និងការកែលម្អគុណភាព និងសុវត្ថិភាព ដើម្បីធានាថាពួកគេអាចប្រើសេវាទាំងនេះដោយមានទំនុកចិត្ត។

យើងមានវិស័យគាំទ្រមតិខ្លាំងក្លាស្តីពីពិការភាពរួចទៅហើយ ក៏ប៉ុន្តែយើងអាចធ្វើឲ្យបានកាន់តែច្រើនថែមទៀត។ ការមានកិច្ចការពារត្រឹមត្រូវ និងកិច្ចការពារជាសកលដើម្បីលើកកម្ពស់ និងការពារសិទ្ធិរបស់ប្រជាជន គឺជាស្នូលកណ្តាលនៃសង្គមមួយដែលយុត្តិធម៌ ហើយត្រឹមត្រូវ។ ការនេះផ្តល់នូវការត្រួតពិនិត្យដែលធានាឲ្យបាននូវសេចក្តីថ្លៃថ្នូរ និងសិទ្ធិរបស់ប្រជាជនត្រូវបានការពារ និងធានាថាមានគ្រឹះយ៉ាងរឹងមាំ ដែលគាំទ្រដល់ការដាក់បញ្ចូលគ្រប់ទិដ្ឋភាពទាំងអស់នៃជីវិត។

យើងកំពុងអនុវត្តការងារដើម្បីកែលម្អលទ្ធភាពទទួលបាន និងការឆ្លើយតបនៃប្រព័ន្ធសេវាកម្មជាច្រើនភេទ។ ការនេះរួមបញ្ចូលទាំងការប្តេជ្ញាចិត្តក្នុងការអប់រំបញ្ចូលគ្នា និងការគាំទ្រសម្រាប់កុមារ និងយុវជនពីការក្រោមការអប់រំរបស់រដ្ឋាភិបាល និងផែនការស្តីពីតម្រូវការពិសេសសម្រាប់សាលារដ្ឋវិចតូរីយ៉ា។

សេវាសុខភាព និងសហគមន៍ដែលឧបត្ថម្ភដោយរដ្ឋ កំពុងត្រូវបានដាក់ស្នើឲ្យកែលម្អ លទ្ធភាពទទួលបានសម្រាប់ជនពិការជាផ្នែកមួយនៃការផ្តល់ការថែទាំ មានគុណភាព និងផ្តោតលើមនុស្សជាចម្បង។

រដ្ឋាភិបាលកំពុងបន្តកែលម្អលទ្ធភាពទទួលបានសេវាដឹកជញ្ជូនសម្រាប់ពលរដ្ឋវិចតូរីយ៉ាទាំងអស់។ ការនេះរួមបញ្ចូលទាំងការលុបបំបាត់នូវឧបសគ្គផ្នែករាងកាយ ការកែលម្អគុណភាពសេវា និងការធានាថាលទ្ធភាពទទួលបាន គឺមានសារសំខាន់ចំពោះរបៀបដែលយើងរចនា រៀបចំ និងពង្រីកបណ្តាញសេវាដឹកជញ្ជូនរបស់យើង។

រដ្ឋាភិបាលក្នុងតំបន់ក៏កំពុងដឹកនាំផងដែរ ដើម្បីបង្កើនលទ្ធភាពនៃអាជីវកម្មក្នុងតំបន់ ដូចជាការធ្វើការជាមួយពាណិជ្ជករក្នុងតំបន់ ដើម្បីកែលម្អ លទ្ធភាពចូលទៅកាន់មណ្ឌលផ្សារទំនើបក្នុងតំបន់ រួមទាំងហាងកាហ្វេ និងភោជនីយដ្ឋាន ដើម្បីធានាថាជនពិការអាចទិញទំនិញ និងបរិភោគអាហារក្នុងតំបន់។

### គំនិតមួយចំនួនអំពីកិច្ចការសំខាន់ៗដែលអាចធ្វើឡើង ក្នុងរយៈពេលបួនឆ្នាំបន្ទាប់ រួមមាន៖

- ការពង្រឹងសមត្ថភាពនៃវិស័យគាំទ្រមតិស្តីពីពិការភាព ដើម្បីដោះស្រាយបញ្ហាជាលក្ខណៈបុគ្គល និងជាប្រព័ន្ធ
- រួមទាំងសកម្មភាពទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារជនពិការ ដូចជាកម្មវិធីបណ្តុះបណ្តាល និងអប់រំនៅក្នុងក្របខណ្ឌយុទ្ធសាស្ត្រដើម្បីទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារទូទាំងរដ្ឋ
- ការបង្កើនជម្រើសទទួលបានលំនៅដ្ឋានទាំងនៅក្នុងទីផ្សាររដ្ឋ និងឯកជន
- ការផ្សព្វផ្សាយគោលការណ៍ជាសកលសម្រាប់ការអនុវត្តន៍ការធ្វើផែនការ និងការកសាងទីក្រុងទាំងអស់
- ការធានាថាសាលារដ្ឋទាំងអស់ដែលទើបសាងសង់ថ្មីៗ ត្រូវបានរចនាឡើង សមស្របទៅតាមតម្រូវការផ្សេងៗរបស់សិស្សានុសិស្ស
- ការកែលម្អ និងការបង្កើនការបណ្តុះបណ្តាលសម្រាប់អ្នកអប់រំកុមារ និងគ្រូបង្រៀន ដើម្បីបំពេញសេចក្តីត្រូវការរបស់កុមារពិការ
- ការកែលម្អលទ្ធភាពទទួលបានព័ត៌មានតាមអនឡាញរបស់រដ្ឋាភិបាល
- ការដាក់បញ្ចូលការឆ្លើយតបទៅនឹងតម្រូវការរបស់ជនពិការ ប្រកបដោយគុណភាពស្តង់ដា និងការទិញសម្រាប់សេវាសាធារណៈសំខាន់ៗ
- ការអភិវឌ្ឍន៍យុទ្ធសាស្ត្រដើម្បីដោះស្រាយបញ្ហាឥរិយាបទ និងអាកប្បកិរិយា ជាសាធារណៈដែលមិនសមរម្យ ហើយគ្មានការគោរព
- កិច្ចខិតខំប្រឹងប្រែងបន្ថែមដែលបានកំណត់ដើម្បីធានាថាជនពិការមានលទ្ធភាពទទួលបានសេវាសុខភាព និងការពិនិត្យសុខភាពដែលអាចការពារបានប្រកបដោយប្រសិទ្ធភាព។

### សំណួរ៖

- តើអ្នកឃើញអ្វីដែលជាបញ្ហាសមភាពសំខាន់បំផុតដែលត្រូវដោះស្រាយ?
- តើយើងគួរតែវាស់ស្ទង់ដំណើរការរីកចំរើនដោយរបៀបណា?
- តើរដ្ឋាភិបាលអាចធ្វើអ្វីខ្លះ ដើម្បីធ្វើឲ្យមានការផ្លាស់ប្តូរពិតប្រាកដនៅក្នុងផ្នែកនេះ?
- តើសហគមន៍ និងវិស័យអាជីវកម្មអាចធ្វើអ្វីខ្លះ ដើម្បីធ្វើឲ្យមានការផ្លាស់ប្តូរពិតប្រាកដនៅក្នុងផ្នែកនេះ?

# ប្រធានបទទី៣៖
# ការចូលរួមផ្នែកសេដ្ឋកិច្ច

... ដោយហេតុថា ជនពិការត្រូវការក្លាយ
ជាផ្នែកសំខាន់មួយនៃកម្លាំងពលកម្ម
របស់រដ្ឋវិចតូរីយ៉ា

## ៣៨ភាគរយ

នៃជនពិការដែលមានអាយុធ្វើការបាន បញ្ចប់ថ្នាក់ទី១២ ប្រៀបធៀបជាមួយនឹង

## ៦១ភាគរយ

នៃជនគ្មានពិការភាព។[11]






អូស្ត្រាលីជាប់ចំណាត់ថ្នាក់

## ទី២១

ក្នុងចំណោមបណ្តាប្រទេស OECD ចំនួន ២៩ចំពោះការផ្តល់ការងារជូនជនពិការ។[12]

## ៥៣ភាគរយ

នៃជនពិការនៅក្នុងកម្លាំងពលកម្ម បើប្រៀបធៀបទៅនឹង

## ៨៣ភាគរយ

នៃជនគ្មានពិការភាព។[13]

អត្រាការងារសម្រាប់ជនពិការនៅក្នុងកម្លាំងពលកម្មនៃវិស័យរដ្ឋវិចតូរីយ៉ា បានធ្លាក់ចុះដល់ទៅ

## 3%[14]

11 ក្រសួងសុខាភិបាល និងសេវាមនុស្សសាស្ត្រ ឆ្នាំ២០១៦, ឯកសារអមជាមួយឯកសារពិភាក្សាផែនការពិការភាពនៃរដ្ឋវិចតូរីយ៉ា ឆ្នាំ២០១៧-២០២០, រដ្ឋាភិបាលវិចតូរីយ៉ា ទីក្រុងមែលប៊ន ទំព័រ 19។

12 Ibid,. ទំព័រ 18។

13 Ibid,. ទំព័រ 17។

14 Ibid,. ទំព័រ 18។

# ប្រធានបទទី៣៖ ការចូលរួមក្នុងវិស័យសេដ្ឋកិច្ច

## ប្រការសំខាន់ៗដែលត្រូវដឹង

- ការចូលរួមផ្នែកសេដ្ឋកិច្ច គឺជាមូលដ្ឋានគ្រឹះក្នុងការដាក់បញ្ចូលទៅក្នុងសង្គម ក៏ប៉ុន្តែនៅក្នុងរដ្ឋវិចតូរីយ៉ា៖
  - ៤៣ភាគរយនៃជនពិការ ពឹងផ្អែកលើប្រាក់សោធននិវត្តន៍ ឬប្រាក់ជំនួយពីរដ្ឋាភិបាល ជាប្រភពចម្បងនៃប្រាក់ចំណូលរបស់ពួកគេ បើប្រៀបធៀបទៅនឹង១០ភាគរយនៃជនគ្មានពិការភាព
  - ភាពគ្មានការងារធ្វើគ្រប់គ្រាន់គឺជាប្រធានបទរួមដែលបានរាយការណ៍ដោយជនពិការដែលធ្វើការងារក្រៅម៉ោង។ ករណីនេះឆ្លុះបញ្ចាំងពីប្រាក់ចំណូលជាមធ្យមទាប គឺ៤០០ដុល្លាក្នុងមួយសប្តាហ៍សម្រាប់ជនពិការ បើប្រៀបធៀបទៅនឹង៧៥០ដុល្លាក្នុងមួយសប្តាហ៍ សម្រាប់ជនគ្មានពិការភាព
  - តិចជាង២៧ភាគរយនៃជនពិការមានអាយុចន្លោះពី១៥ និង៦៤ឆ្នាំ មានសញ្ញាបត្របរិញ្ញាបត្រ ឬខ្ពស់ជាងនេះ បើប្រៀបធៀបទៅនឹងប្រហែលជា៤០ភាគរយនៃជនគ្មានពិការភាព
  - មានតែ៤៩.៩នៃជនពិការបញ្ចប់ការអប់រំ និងការបណ្តុះបណ្តាលផ្នែកវិជ្ជាជីវៈមានការងារធ្វើ បន្ទាប់ពីបានបញ្ចប់ការបណ្តុះបណ្តាល បើប្រៀបធៀបទៅនឹង៧៦.២ភាគរយនៃនិស្សិតបញ្ចប់ការសិក្សាជាជនគ្មានពិការភាព។
- អំឡុងពេលពិគ្រោះយោបល់គ្រាដំបូង យើងបានឮម្តងហើយម្តងទៀតថា ជនពិការចង់បានការងារ ហើយពួកគេចង់បានប្រាក់ផ្ទាល់ខ្លួនគេ ដូច្នេះពួកគេអាចធ្វើការជ្រើសរើសដោយផ្ទាល់ខ្លួន។

សម្រាប់ព័ត៌មានបន្ថែម សូមមើលឯកសារអម។

ពលរដ្ឋវិចតូរីយ៉ាដែលជាជនពិការ មានសិទ្ធិទទួលបានការប្រព្រឹត្តដោយយុត្តិធម៌នៅកន្លែងការងារ។

ពួកគេមានសិទ្ធិក្នុងការទទួលបានការអប់រំល្អ។ ពួកគេមានសិទ្ធិក្នុងការសម្រេចបាននូវសក្តានុពលការងាររបស់ខ្លួន។ ហើយពួកគេមានសិទ្ធិក្នុងការទទួលបានប្រាក់បៀវត្សរ៍សមរម្យ។

ជាអកុសល ទោះបីជាយ៉ាងណាក៏ដោយ ជនពិការជាច្រើននាក់មានលទ្ធផលអប់រំអន់ខ្សោយ ដែលកំណត់ផ្លូវលំរបស់ពួកគេឆ្ពោះទៅរកជម្រើសបន្តការសិក្សា និងការងារ។ ហើយជាលទ្ធផល ពួកគេខកខានទទួលបានជំនាញ និងការត្រៀមខ្លួនដែលពួកគេត្រូវការ ដើម្បីចូលរួមនៅក្នុងជីវិតសេដ្ឋកិច្ចនៃសហគមន៍របស់យើង។

មិនត្រឹមតែប៉ុណ្ណោះ ជនពិការអាចប្រឈមនឹងឧបសគ្គជាច្រើនខាងផ្នែករាងកាយ និងឥរិយាបទក្នុងការចូលរួមក្នុងកម្លាំងពលកម្ម។ ការកាត់បន្ថយការប្រកាន់រើសអើងនៅកន្លែងធ្វើការ - ក្នុងការទទួលបានការងារ ក្នុងការរក្សាការងារ ឬក្នុងការកសាងអាជីព - មិនត្រឹមតែល្អសម្រាប់បុគ្គល ថែមទាំងល្អសម្រាប់សេដ្ឋកិច្ចផងដែរ។ ការកែលម្អលទ្ធផលការងារសម្រាប់ជនពិការអាចបង្កើនផលិតផលក្នុងស្រុកសរុប និងបង្កើតកន្លែងធ្វើការកាន់តែមានផលិតភាព។ ការមានជនពិការជាច្រើននាក់ ធ្វើការជាម្ចាស់អាជីវកម្មដែលមានសមត្ថភាព និងជាអ្នកប្រើប្រាស់ ក៏នឹងជំរុញឲ្យមានសកម្មភាពសេដ្ឋកិច្ចផងដែរ។

យើងចង់បានរដ្ឋវិចតូរីយ៉ា ជាទីកន្លែងដែលជនពិការរស់នៅដោយឯករាជ្យ ស្វែងរកអត្តសញ្ញាណ និងឋានៈរបស់ខ្លួនក្នុងសហគមន៍ ហើយធានានូវអនាគតសេដ្ឋកិច្ចរបស់ពួកគេ។

NDIS នឹងបង្កើតឱកាសថ្មីៗសម្រាប់ជនពិការចូលរួមក្នុងសេដ្ឋកិច្ច - មិនថាជាកម្មករ និយោជក សហគ្រិន អ្នកវិនិយោគ ឬអ្នកប្រើប្រាស់ឡើយ។

ដើម្បីបង្កើនជាអតិបរមា នូវផលប្រយោជន៍សេដ្ឋកិច្ចច្រើនសន្ធឹកសន្ធាប់នៃ NDIS ទោះបីជាតម្រូវការបន្ថែមទៀតក្តី ដែលត្រូវធ្វើឡើងដើម្បីទម្លុះឧបសគ្គ ដើម្បីធានាឲ្យមានទីកន្លែងធ្វើការរួមបញ្ចូលទាំងទីកន្លែងធ្វើការនៅក្នុងវិស័យសាធារណៈ និងឯកជនត្រូវបញ្ចូលគ្នា និងឆ្លុះបញ្ចាំងពីភាពចម្រុះនៃពលរដ្ឋវិចតូរីយ៉ាទាំងអស់។

យើងបានធ្វើការវាយលុកមួយចំនួន ក៏ប៉ុន្តែបញ្ហាប្រឈម និងឱកាសជាច្រើន ស្ថិតនៅខាងមុខយើង។ ឧទាហរណ៍ ក្រសួងរដ្ឋាភិបាលមួយចំនួន បានសហការជាមួយបណ្តាញអូស្ត្រាលីស្តីពីពិការភាពដើម្បីផ្តល់កន្លែងសិក្សា ‘Stepping into“ សម្រាប់និស្សិតពិការ ក្នុងគោលបំណងផ្តល់ឲ្យពួកគេនូវបទពិសោធន៍ដ៏មានតម្លៃក្នុងវិស័យការងាររដ្ឋវិចតូរីយ៉ា។

**គំនិតមួយចំនួនអំពីកិច្ចការសំខាន់ដែលអាចធ្វើឡើង ក្នុងរយៈពេលបួនឆ្នាំបន្ទាប់ រួមមាន៖**

- ការបង្កើតផែនការសកម្មភាពជាក់លាក់ ដើម្បីបង្កើនការចូលរួមផ្នែកសេដ្ឋកិច្ច ពីជនពិការនៅក្នុងរដ្ឋវិចតូរីយ៉ា ដោយមានកិច្ចសហការជាមួយវិស័យអាជីវកម្ម
- ការពង្រីកលទ្ធភាពទទួលបានការអភិវឌ្ឍន៍ជំនាញ និងការគាំទ្រការងារដើម្បីជួយដល់ជនពិការ ក្នុងការធានាឲ្យបានការងារប្រកបដោយនិរន្តរភាព
- ការពង្រឹងការគាំទ្រដល់គ្រូបង្រៀន និងសាលារៀនដើម្បីបំពេញតម្រូវការរបស់សិស្សពិការ
- ការកែលម្អលទ្ធផលសិក្សា និងការចូលរួមសម្រាប់សិស្សពិការ តាមរយៈការផ្តួចផ្តើមគំនិតក្នុងផែនការតម្រូវការពិសេសសម្រាប់សាលារដ្ឋវិចតូរីយ៉ា
- ការធ្វើការជាមួយនិយោជក ដើម្បីពង្រឹងទីកន្លែងធ្វើការដែលមានលក្ខណៈបញ្ចូលគ្នា និងចម្រុះ
- ការដាក់ឥទ្ធិពលលើអ្នកផ្គត់ផ្គង់ ដើម្បីអនុម័តនូវការអនុវត្តន៍ដែលនឹងបង្កើនការចូលរួមផ្នែកសេដ្ឋកិច្ចរបស់ជនពិការតាមរយៈការបង្កើនតួនាទីរបស់រដ្ឋាភិបាល ជាអ្នកទិញចម្បងនៃទំនិញ និងសេវាកម្ម
- ការអភិវឌ្ឍន៍យុទ្ធសាស្ត្រ ដើម្បីបង្កើនការងាររបស់ជនពិការនៅក្នុងការងាររដ្ឋវិចតូរីយ៉ា។

**សំណួរ៖**

- តើអ្នកគិតថា គួរធ្វើអ្វីខ្លះដើម្បីលើកកម្ពស់ការចូលរួមផ្នែកសេដ្ឋកិច្ចសម្រាប់ជនពិការ?
- តើយើងគួរតែវាស់ស្ទង់ដំណើរការរីកចំរើនដោយរបៀបណា?
- តើរដ្ឋាភិបាលអាចធ្វើអ្វីខ្លះ ដើម្បីធ្វើឲ្យមានការផ្លាស់ប្តូរពិតប្រាកដនៅក្នុងផ្នែកនេះ?
- តើសហគមន៍ និងវិស័យអាជីវកម្មអាចធ្វើអ្វីខ្លះ ដើម្បីធ្វើឲ្យមានការផ្លាស់ប្តូរពិតប្រាកដនៅក្នុងផ្នែកនេះ?

# ប្រធានបទទី៨៖
# ការប្រើប្រាស់ NDIS អស់ពីលទ្ធភាព

... ដោយហេតុតែសេវាចម្បងគឺមាន
សារសំខាន់ចំពោះភាពជោគជ័យ
របស់គម្រោង

# ផែនទីដំណើរការ NDIS សម្រាប់រដ្ឋវិចតូរីយ៉ា

រដ្ឋវិចតូរីយ៉ានឹងមានដំណើរការ NDIS ជាដំណាក់កាល ចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៦។

| 2015 | 2016 | 2017 | 2018 | 2019 |
|---|---|---|---|---|
| Barwon ✓ | North Eastern Melbourne | Western District | Hume Moreland | Outer Gippsland |
| | | Central Highlands | Brimbank Melton | Mallee |
| | | Loddon | Western Melbourne | Goulburn |
| | | Inner Gippsland | Bayside Peninsula | |
| | | Inner Eastern Melbourne | Southern Melbourne | |
| | | Outer Eastern Melbourne | | |
| | | Ovens Murray | | |



# ប្រធានបទទី៨៖
# ការប្រើប្រាស់ NDIS ឲ្យអស់ពីលទ្ធភាព

## ប្រការសំខាន់ៗដែលត្រូវដឹង

- រដ្ឋាភិបាលវិចតូរីយ៉ានឹងវិនិយោគ២.៥ពាន់លានដុល្លា ក្នុងមួយឆ្នាំ សម្រាប់ NDIS ដើម្បីគាំទ្រដល់ជនពិការ ក្នុងរដ្ឋវិចតូរីយ៉ា ក្រុមគ្រួសាររបស់ពួកគេ អ្នកផ្តល់សេវា និងបុគ្គលិក ហើយនិងផ្តល់បណ្តាញសុវត្ថិភាពនៃពិការភាពសម្រាប់ពលរដ្ឋវិចតូរីយ៉ាទាំងអស់។
- NDIS គឺជាកម្មវិធីជាតិដែលនឹងផ្តល់វិធីថ្មីនៃការផ្តល់សេវា និងការគាំទ្រសម្រាប់ជនពិការអចិន្ត្រៃយ៍ និងធ្ងន់ធ្ងរនៅក្នុងប្រទេសអូស្ត្រាលី។
- ជនពិការដែលបានចូលរួមក្នុង NDIS អាចជ្រើសរើសការគាំទ្រ និងសេវាកម្មដែលបំពេញតាមតម្រូវការបុគ្គលរបស់ពួកគេ ជាជាងចូលរួមក្នុងប្រព័ន្ធទំហំមួយត្រូវទាំងអស់។
- NDIS នេះនឹងត្រូវបានដំណើរការជាបន្តបន្ទាប់នៅក្នុងរដ្ឋវិចតូរីយ៉ារយៈពេលបីឆ្នាំ ចាប់ពីខែកក្កដា ឆ្នាំ២០១៦។
- គម្រោងនេះមានការផ្តល់ជូនសម្រាប់ពលរដ្ឋវិចតូរីយ៉ាដែលមានពិការភាព ឬមានជំងឺប្រចាំកាយជាអចិន្ត្រៃយ៍ ហើយ៖
    - មានលំនៅដ្ឋានក្នុងប្រទេសអូស្ត្រាលី
    - នៅក្រោមអាយុ៦៥ឆ្នាំ
    - ត្រូវការការគាំទ្រពីមនុស្សម្នាក់ ឬបរិក្ខារដើម្បីធ្វើសកម្មភាពប្រចាំថ្ងៃ។
- សូមចូលមើលវិបសាយ NDIS សម្រាប់ព័ត៌មានបន្ថែម៖ www.vic.gov.au/ndis

ផែនការពិការភាពនៃរដ្ឋវិចតូរីយ៉ា គឺអំពីការបង្កើនការដាក់បញ្ចូលទៅក្នុងរដ្ឋវិចតូរីយ៉ា និងលទ្ធភាពទទួលបានតាមរយៈចំណាត់ការជាក់ស្តែងក្នុងរយៈពេលបួនឆ្នាំខាងមុខ។

ក្នុងពេលទន្ទឹមគ្នានេះដែរ រដ្ឋវិចតូរីយ៉ានឹងដាក់ដំណើរការ NDIS ដែលចាប់ផ្តើមនៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៦ ហើយនឹងបន្តទៅកាន់ទីតាំងភូមិសាស្ត្រ ក្នុងរយៈពេលបីឆ្នាំខាងមុខនេះ។

NDIS គឺជាវិធីថ្មីនៃការផ្តល់ការគាំទ្រដល់ជនពិការអចិន្ត្រៃយ៍ ហើយធ្ងន់ធ្ងរក្រុមគ្រួសារ និងអ្នកថែទាំរបស់ពួកគេ ដើម្បីឲ្យពួកគេមានសេចក្តីថ្លៃថ្នូរ ជម្រើសនៃរបៀបរស់នៅ និងកិច្ចការពារសិទ្ធិមនុស្សដែលយើងភាគច្រើនពុំសូវឲ្យតម្លៃ។

ក្នុងអំឡុងពេលនៃផែនការរដ្ឋ ស្តីពីពិការភាពនៅពេលបន្ទាប់ វានឹងក្លាយជាអាទិភាពមួយសម្រាប់យើងដើម្បីកែតម្រូវ NDIS។

មកត្រឹមខែកក្កដា ឆ្នាំ២០១៩ នឹងមានពលរដ្ឋវិចតូរីយ៉ាប្រហែលជា១០៥,០០០នាក់ មានលទ្ធភាពទទួល NDIS។ លើសពីនេះទៀតមួយក្រុមធំនៃជនពិការនឹងទទួលបានព័ត៌មាន និងសកម្មភាពគាំទ្រដែលឧបត្ថម្ភដោយ NDIS។

ពលរដ្ឋវិចតូរីយ៉ាដែលមានពិការភាព រួមទាំងប្រជាជនដែលចូលរួមនៅក្នុង NDIS នឹងបន្តទទួលបានសេវាកម្មពីប្រព័ន្ធចម្បង ដូច្នេះយើងត្រូវបន្តធ្វើការលើ លទ្ធភាពទទួលបាន និងលទ្ធភាពប្រើប្រាស់សេវាកម្មចម្បងរបស់យើង។

ការនេះនឹងជួយយើងកែលម្អលទ្ធផលសម្រាប់ជនពិការ ក្នុងវិស័យនានាដូចជាសុខាភិបាល ការអប់រំ ការងារ និងលំនៅដ្ឋាន។

យើងក៏នឹងត្រូវធានាដែរថា មានការសម្របសម្រួលយ៉ាងមានប្រសិទ្ធភាពរវាងសេវាកម្មចម្បង និង NDIS។

### សំណួរ៖

- តើអ្នកគិតថាអ្វីជាវិធីមានសារសំខាន់ដែលនៅក្នុងនោះ រដ្ឋាភិបាលអាចជួយពលរដ្ឋវិចតូរីយ៉ាទទួលបាន អត្ថប្រយោជន៍ច្រើនបំផុតពី NDIS?
- តើអ្នកគិតថាអ្វីជាវិធីមានសារសំខាន់ដែលនៅក្នុងនោះ វិស័យអាជីវកម្ម និងសហគមន៍ អាចជួយពលរដ្ឋ វិចតូរីយ៉ាទទួលបានអត្ថប្រយោជន៍ច្រើនបំផុតពី NDIS?

# ការជំរុញឲ្យមានលទ្ធផល

... ដោយហេតុតែយើងទាំងអស់គ្នា
ដើរតួនាទីក្នុងការសម្រេចបាននូវ
លទ្ធផលល្អប្រសើរជាងមុន

"ដោយហេតុតែគ្មានបទដ្ឋានគ្រឹះ គ្មាននរណាម្នាក់អាចទទួលខុសត្រូវចំពោះការមិនបានសម្រេចនូវបទដ្ឋានគ្រឹះឡើយ។"

*របាយការណ៍ស៊ើបអង្កេតលើការដាក់បញ្ចូលទៅក្នុងសង្គម*

"សិទ្ធិក្នុងការគ្រប់គ្រងគឺជាឯកសិទ្ធិ ហើយមិនត្រូវមើលរំលងឡើយ។ រដ្ឋាភិបាលក៏ត្រូវតែមានភាពស្មោះត្រង់ និងមានភាពច្បាស់ងាយយល់។"

*របាយការណ៍ស៊ើបអង្កេតលើការដាក់បញ្ចូលទៅក្នុងសង្គម*

ច្រើនជាង

# ៨០ភាគរយ

ពលរដ្ឋអូស្ត្រាលី ប្រើប្រាស់អ៊ិនធើណិត។[15]

"ការផ្លាស់ប្តូរយ៉ាងឆាប់រហ័សក្នុងការប្រើប្រាស់បច្ចេកវិទ្យាដំណើរការដោយអ៊ិនធើណិត អាចផ្តល់សិទ្ធិអំណាចដល់ជនពិការ។"

*របាយការណ៍ស៊ើបអង្កេតលើការដាក់បញ្ចូលទៅក្នុងសង្គម*

15 ក្រសួងសុខាភិបាល និងសេវាមនុស្សសាស្ត្រ ឆ្នាំ២០១៦, ឯកសារអមជាមួយឯកសារពិភាក្សាផែនការពិការភាពនៃរដ្ឋវិចតូរីយ៉ា ឆ្នាំ២០១៧-២០២០, រដ្ឋាភិបាលវិចតូរីយ៉ា ទីក្រុងមែលប៊ន ទំព័រទី 16។

# ការជំរុញឲ្យមានលទ្ធផល

រដ្ឋវិចតូរីយ៉ាចង់ឃើញលទ្ធផលប្រសើរជាងមុនសម្រាប់ជនពិការ។

ប្រសិនបើ ក្នុងភាពជាជារដ្ឋមួយ យើងយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះការដាក់បញ្ចូលដែលជនពិការជាច្រើននាក់ក្នុងរដ្ឋវិចតូរីយ៉ាបានជួបប្រទះ នោះរដ្ឋាភិបាលចាំបាច់ត្រូវនាំមុខ។

យើងបានអនុវត្តផែនការសកម្មភាពស្តីពីពិការភាពរួចហើយ នៅក្នុងបណ្តារដ្ឋាភិបាល និងសាលាក្រុងភាគច្រើន។

នេះជាជំហានមួយក្នុងទិសដៅត្រឹមត្រូវ។ ទោះជាយ៉ាងណាក៏ដោយ យើងត្រូវពង្រីកខាងធ្វើកិច្ចខិតខំប្រឹងប្រែងរួមនៅគ្រប់កម្រិតទាំងអស់។

យើងក៏ត្រូវតាមដានលើការរីកចម្រើនរបស់យើងផងដែរ។

យើងត្រូវតែមានភាពច្បាស់ងាយយល់ ហើយបើកចំហអំពីចំណាត់ការដែលកំពុងអនុវត្ត។

យើងត្រូវសហការជាមួយបណ្តាក្រុមហ៊ុនអាជីវកម្ម និងសហគមន៍នានា ដើម្បីជំរុញឲ្យមានចំណាត់ការ។

ហើយយើងត្រូវវាស់ស្ទង់លទ្ធផលនៃចំណាត់ការទាំងនោះ។

**គំនិតមួយចំនួនអំពីកិច្ចការសំខាន់ៗដែលអាចធ្វើឡើង ក្នុងរយៈពេលបួនឆ្នាំខាងមុខ រួមមាន៖**

- ការដាក់បញ្ចូលការរៀបចំផែនការពិការភាពនៅក្នុងជួររដ្ឋាភិបាលថ្នាក់រដ្ឋ និងតាមតំបន់ រួមទាំងក្រសួងរដ្ឋទាំងអស់ និងអាជ្ញាធរស្របច្បាប់ពាក់ព័ន្ធ
- ការអភិវឌ្ឍន៍ក្របខណ្ឌលទ្ធផលជាមួយវិធានការ និងគោលដៅច្បាស់លាស់ ដើម្បីជំរុញឲ្យមានការទទួលខុសត្រូវពីវិស័យសាធារណៈកាន់តែច្រើន
- ការពង្រឹងប្រព័ន្ធផ្សព្វផ្សាយសង្គម និងវេទិកាបណ្តាញសង្គម ដើម្បីចូលរួមជាមួយប្រជាជន ហើយកំណត់បញ្ហា និងឧបសគ្គជាប្រព័ន្ធ
- ការពង្រឹងភាពច្បាស់ងាយយល់ តាមរយៈការរាយការណ៍ជាសាធារណៈ។

**សំណួរ៖**

- តើរដ្ឋាភិបាលអាចធ្វើអ្វីខ្លះដើម្បីជំរុញឲ្យមានការទទួលខុសត្រូវចំពោះលទ្ធផល?
- តើរដ្ឋាភិបាលវាស់ស្ទង់ផលប៉ះពាល់នៃផែនការនេះដោយរបៀបណា?
- តើជនពិការចូលរួមក្នុងដំណើរការនេះដោយរបៀបណា?

# សេចក្ដីសន្និដ្ឋាន

ផែនការពិការភាពនៃរដ្ឋវិចតូរីយ៉ា ឆ្នាំ២០១៧-២០២០ កំពុងត្រូវបានអភិវឌ្ឍ ហើយនឹងត្រូវបានអនុវត្តក្នុងអំឡុងពេលផ្លាស់ប្ដូរយ៉ាងសំខាន់ក្នុងផ្នែកពិការភាព នៅក្នុងរដ្ឋវិចតូរីយ៉ា។

ផែនការ និងសកម្មភាពពាក់ព័ន្ធនឹងត្រូវសម្របសម្រួល ហើយផ្លាស់ប្ដូរ ខណៈបរិស្ថានប្រែប្រួលជាលទ្ធផលនៃ NDIS។

ផែនការនេះនឹងក្លាយជាផែនការលម្អិតរបស់យើង សម្រាប់ធ្វើកំណែទម្រង់ដែលចាំបាច់ត្រូវធ្វើឡើង ដើម្បីបង្កើនអត្ថប្រយោជន៍ជាអតិបរមានៃ NDIS។

ឯកសារពិភាក្សានេះ គូសបញ្ជីពីគំនិតមួយចំនួនរបស់រដ្ឋាភិបាលវិចតូរីយ៉ា ក៏ប៉ុន្តែយើងត្រូវការដឹងឮពីពលរដ្ឋវិចតូរីយ៉ាមកពីគ្រប់មជ្ឈដ្ឋាន។

យើងចង់បានគំនិត និងទស្សនៈវិស័យរបស់អ្នកសម្រាប់ពេលអនាគត។

ផែនការពិការភាពរបស់រដ្ឋ នឹងត្រូវបានចេញផ្សាយនៅខែធ្នូ ហើយចូលជាធរមានចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៧។

ការរួមចំណែកទាំងអស់ នឹងជួយយើងបញ្ចប់ផែនការនេះ។

ការចូលរួមពីសហគមន៍កាន់តែច្រើន លទ្ធផលសម្រាប់ពលរដ្ឋវិចតូរីយ៉ាទាំងអស់ កាន់តែល្អប្រសើរ។

ដើម្បីស្វែងយល់បន្ថែម៖

**www.statedisabilityplan.vic.gov.au**